អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## លោកស្រី Megan Hirst ត្រូវបានជ្រើសរើសជាសហមេធាវីនាំមុខអន្តរជាតិថ្មីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រី Megan Hirst ជនជាតិអូស្ត្រាលី ត្រូវបានជ្រើសរើសជាសហមេធាវីនាំមុខអន្តរជាតិថ្មីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ លោកស្រី Megan Hirst ជំនួសតំណែងលោកស្រី Marie Guiraud (ជនជាតិបារាំង) ដែលបានលាលែងពីមុខតំណែងកាលពីខែ មិថុនា ឆ្នាំ២០១៩ ដែលមានសុពលភាពចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

លោកស្រី Hirst មានបទពិសោធន៍បម្រើការងារក្នុងវិស័យច្បាប់សិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ រយៈពេល ១៥ឆ្នាំ។ លោកស្រីមានបរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យ Queensland និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យ Cambridge។ រយៈពេលដប់ឆ្នាំកន្លងទៅ លោកស្រី Hirst បានក្លាយជាអ្នកជំនាញផ្នែកការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ។ លោកស្រីបានតំណាងឲ្យជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នៅក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dominic Ongwen និងនៅក្នុងកិច្ចដំណើរការនីតិវិធីនានាមុនការជំនុំជម្រះ ទាក់ទិនទៅនឹងស្ថានភាពនៅក្នុងប្រទេសបង់ក្លាដេស/មីយ៉ានម៉ា និងស្ថានភាពនៅក្នុងប្រទេសអាហ្វហ្គានីស្ថង់។កាលពីមុន លោកស្រីធ្លាប់បម្រើការងារជាក្រឡាបញ្ជីនៅអង្គភាពជនរងគ្រោះ និងសំណងនៃតុលាការ ICC និងនៅអង្គភាពជនរងគ្រោះនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់។ លោកស្រីជាសហអ្នកពិនិត្យកែសម្រួលសៀវភៅដែលមានចំណងជើងថា ការចូលរួមរបស់ជនរងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ហើយបច្ចុប្បន្ននេះ លោកស្រីបម្រើការងារជាសហអនុប្រធានផ្នែកជនរងគ្រោះនៃគណៈមេធាវីនៃតុលាការ ICC (ឆ្នាំ២០១៩-ឆ្នាំ២០២០)។

លោកស្រី ក៏ប្រកបវិជ្ជាជីវៈមេធាវីនៅគណៈមេធាវីប្រទេសអង់គ្លេស និងប្រទេសវ៉ែល ផងដែរ ដោយលោកស្រីតំណាងឲ្យជនរងគ្រោះចំពោះការសួរដេញដោលជាសាធារណៈទៅលើការរំលោភបំពានផ្លូវភេទ។ ក្រៅពីការងារជាមេធាវី លោកស្រី Hirst ទទួលបន្ទុករៀបចំគម្រោងអន្តរជាតិនានាជាប្រចាំ ទាក់ទិននឹងសិទ្ធិមនុស្ស និងការវិវត្តន៍វិធាន

គតិយុត្តិ។ លោកស្រីមានបទពិសោធន៍យ៉ាងច្រើននៅទីម័រខាងកើត ដោយលោកស្រីបម្រើការងារ តាំងពីឆ្នាំ២០០៥ ពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងអំពើឃោរឃៅជាទ្រង់ទ្រាយធំ និងការពង្រឹងវិស័យយុត្តិធម៌។

លោកស្រី Hirst នឹងធ្វើការជាមួយលោក ពេជ អង្គ ដែលជាសហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។ ដើមបណ្តឹងរដ្ឋប្បវេណីធានាឲ្យមានការរៀបចំតំណាងប្រកបដោយប្រសិទ្ធភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនានានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែលអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងធ្វើការទាមទារសំណងផ្លូវចិត្ត និងសំណងសមូហភាព។ ការទទួលខុសត្រូវចម្បងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមមាន តំណាងឲ្យផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ ផ្តល់នូវការអះអាង និងយុទ្ធសាស្រ្តជាទូទៅ ព្រមទាំងតំណាងនៅចំពោះមុខតុលាការអំពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ។

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***


លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(០)១២៤៨៨១៥៦
អ៊ីមែល: neth.pheaktra@eccc.gov.kh